ព្រះរាជក្រឹត្យ

នស/រកត/០៥០៦/២១៤

ស្តីពី

ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស . រកត . ០៧០៤ . ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩ នស.៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ ក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១២ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០០៤/០០៤ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈពេលនៃកម្ពុជាប្រជាធិបតេយ្យ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០០៤/០០៦ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យច្បាប់ ស្តីពីការបង្កើតឱ្យមានសាលាក្តីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាព ពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៦

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានតែងតាំងសមាសភាព ចៅក្រមសាលាដំបូង តុលាការកំពូល សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងអង្គបុរេជំនុំជំរះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដូចខាងក្រោម :

១. ចៅក្រមសាលាដំបូង

| | |
|---|---|
| - លោក និល ណុន | ជាចៅក្រម |
| - លោក ធូ មុនី | ជាចៅក្រម |
| - លោក យ៉ា សុខន | ជាចៅក្រម |
| - M$^{me}$ Silvia CARTWRIGHT (New-Zealand) | ជាចៅក្រម |
| - M$^{R}$ Jean-Mare LAVERGNE (France) | ជាចៅក្រម |
| - លោក យូ អុត្តរា | ជាចៅក្រមបំរុង |
| - M$^{me}$ Claudia FENZ (Autriche) | ជាចៅក្រមបំរុង |

២. តុលាការកំពូល

| | |
|---|---|
| - ឯកឧត្តម គង់ ស្រ៊ីម | ជាចៅក្រម |
| - លោក សោម សេរីវុឌ្ឍ | ជាចៅក្រម |
| - លោក ស៊ិន រិទ្ធ | ជាចៅក្រម |
| - លោក យ៉ា ណារិន | ជាចៅក្រម |
| - M$^{R}$ MOTOO NOGUCHI (Japan) | ជាចៅក្រម |
| - M$^{me}$ Agnieska KLONOWIECKA-MILART (Pologne) | ជាចៅក្រម |
| - M$^{R}$ Chandra Nihal Jayasinghe (Sri-Lanka) | ជាចៅក្រម |
| - លោក ម៉ុង មុន្នីចារិយា | ជាចៅក្រមបំរុង |
| - M$^{R}$ Martin KAROPKIN (USA) | ជាចៅក្រមបំរុង |

៣. សហចៅក្រមស៊ើបអង្កេត

| | |
|---|---|
| - លោក យូ ប៊ុនឡេង | ជាសហចៅក្រមស៊ើបអង្កេត |
| - M$^{R}$ Marcel LEMONDE (France) | ជាសហចៅក្រមស៊ើបអង្កេត |
| - លោក ថុង អុល | ជាសហចៅក្រមស៊ើបអង្កេតបំរុង |

៤. សហព្រះរាជអាជ្ញា

| | |
|---|---|
| - លោកស្រី ជា លាង | ជាសហព្រះរាជអាជ្ញា |
| - M$^{R}$ Robert PETIT (Canada) | ជាសហព្រះរាជអាជ្ញា |
| - ឯកឧត្តម ជួន ស៊ុនឡេង | ជាសហព្រះរាជអាជ្ញាបំរុង |
| - M$^{R}$ Paul COFFEY (USA) | ជាសហព្រះរាជអាជ្ញាបំរុង |

៥. អង្គបុរេជំនុំជម្រះ

- ឯកឧត្តម ប្រាក់ គឹមសាន ជាចៅក្រម
- ឯកឧត្តម នំយ ថុល ជាចៅក្រម
- លោក ហួត វុទ្ធី ជាចៅក្រម
- M[R] Rowan DOWNING (Australia) ជាចៅក្រម
- M[me] Katinka LAHUIS (Netherlands) ជាចៅក្រម
- លោក ប៉ែន ពេជ្រសាលី ជាចៅក្រមបំរុង

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស.០៦០៥.២២៤

រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែឧសភា ឆ្នាំ ២០០៦

លេខៈ ២០៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់